00157757

ឯកសារ/No: A121

# នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស

បញ្ជូនទៅ: សហចៅក្រមស៊ើបអង្កេត

កាលបរិច្ឆេទនៃការបញ្ជូន: ថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨

ភាគីបញ្ជូន: សហមេធាវីការពារលោក អៀង សារី

ភាសាដើម: ភាសាខ្មែរ និង អង់គ្លេស

ប្រភេទឯកសារ: សម្ងាត់ សាធារណៈ 01/06/2009

CO-JUDGES GREFFIER CO-JUGES D'INSTRUCTION

---

## សំណើសុំព័ត៌មានទាក់ទងនឹងធនធានសំខាន់ៗដែលប្រយោជន៍មានសក្ដានុពល

---

<u>បញ្ជូនដោយ៖</u>

សហមេធាវីការពារលោក អៀង សារី

មេធាវី អាង ឧត្តម

មេធាវី Michael G. KARNAVS

<u>ចែកចាយជូន៖</u>

សហចៅក្រមស៊ើបអង្កេត

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Marcel LEMONDE

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 10 / 01 / 2008
ម៉ោង (Time/Heure): 13h 20 PM
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 05 / 06 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

00157758





យើងខ្ញុំមានចំណាប់អារម្មណ៍ថា សមាជិកម្នាក់នៃការិយាល័យសហចៅក្រមស៊ើបអង្កេត ជាពិសេស លោក **ស្ទីវេន ហេដ័រ** ប្រហែលជាធ្លាប់បានធ្វើការជាមួយការិយាល័យសហព្រះរាជអាជ្ញា នៅមុនពេលដែលគាត់មកធ្វើការងារជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត ។

តាមរយៈលិខិតនេះ យើងខ្ញុំមានបំណងចង់អោយយើងទាំងអស់គ្នាបំពេញកិច្ចការអោយស្របទៅតាមកាតព្វកិច្ចជាវិជ្ជាជីវៈ និងប្រកបដោយក្រមសីលធម៌ ។ ចាប់តាំងពីពេលដែលការិយាល័យសហចៅក្រមស៊ើបអង្កេត ជា*ការិយាល័យឯករាជ្យ* នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា[1] ហើយដើម្បីអនុវត្តនូវមុខងារស៊ើបអង្កេតរបស់ខ្លួន ការិយាល័យនេះត្រូវតែធ្វើការដោយអនាគតិ[2] ។ យើងខ្ញុំសូមស្នើសុំដោយក្តីគោរពថា ជាការប្រសើរសំរាប់យើងខ្ញុំដើម្បីតាមដានរឿងនេះដើម្បីអោយឃើញថាតើមានចំណាត់ការជាវិជ្ជមានណាមួយត្រូវបានធានាឬទេ? ដូច្នេះហើយ ដើម្បីជាប្រយោជន៍នៃតម្លាភាពពេញលេញ និងដើម្បីបង្កើតនូវប្រវត្តិការណ៍មួយសង្ខេបជាក់លាក់ យើងខ្ញុំស្វែងរកការបំភ្លឺនូវបណ្តាសំនួរមួយចំនួន៖

១. តើលោក **ហេដ័រ** ធ្លាប់ជាសមាជិកនៃការិយាល័យសហព្រះរាជអាជ្ញាឬទេ?

២. បើសិនជាមាន

ក. តើកាលបរិច្ឆេទពិតប្រាកដនៃថ្ងៃធ្វើការងាររបស់គាត់នៅពេលណា?

ខ. តើប្រភេទការងារពិតប្រាកដរបស់គាត់ធ្វើអ្វីនៅពេលនោះ?

គ. តើគាត់ធ្លាប់ចូលរួមក្នុងសមត្ថកិច្ចណាមួយក្នុងការស៊ើបអង្កេត ឬ ដំណើការតាក់តែងសេចក្តីសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ (ត្រួតពិនិត្យ ឬ វិភាគឯកសារ, សំភាសន៍សាក្សី, ចូលរួមក្នុងដំណាក់កាលប្រមូលផ្តុំគំនិត ជាអាទិ៍)?

ឃ. តើលោក **ហេដ័រ** បានលាតត្រដាងដល់ការិយាល័យសហចៅក្រមស៊ើបអង្កេតពីប្រភេទនៃការងារពីមុនរបស់គាត់ មុនពេលដែលគាត់ចាប់ផ្តើមធ្វើការងារជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត?

---

[1] វិធាន ១៤.១ នៃ វិធានផ្ទៃក្នុង សម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

[2] វិធាន ៥៥.៥

ង. តើការិយាល័យសហចៅក្រមស៊ើបអង្កេត បានស្នើអោយលោក ហេដ័រ សសេរជាលាយលក្ខអក្សររំលឹកការចងចាំនូវប្រភេទនៃការងាររបស់គាត់ជាមួយការិយាល័យសហព្រះរាជអាជ្ញា ឬទេ?

ច. តើការទទួលខុសត្រូវរបស់លោក ហេដ័រ ពីមុន និងបច្ចុប្បន្ន មានអ្វីខ្លះ?

៣. តើការិយាល័យសហចៅក្រមស៊ើបអង្កេត ធ្លាប់ពិចារណាថាតើ ការងាររបស់លោក ហេដ័រ ដែលធ្វើជាមួយនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត ធ្វើអោយមានទំនាស់ផលប្រយោជន៍ជាក់ស្តែង ឬដោយវិចារណញ្ញាណ ដែរឬទេ?

សូមលោកចៅក្រមទទួលសំណើនេះដោយក្តីគោរព

មេធាវី អាង ឧត្តម　　　　មេធាវី Michael G. KARNAVAS

សហមេធាវីការពារលោក អៀង សារី

ចុះហត្ថលេខានៅភ្នំពេញ រាជធានីនៃព្រះរាជាណាចក្រកម្ពុជា នាថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៨